# ការដាំដុះគម្របរស់នៅក្នុងផលិតកម្មដំណាំបន្លែ

INTEGRATION OF LIVING MULCH IN VEGETABLE PRODUCTION

កុម្ភៈ ២០២២ | FEBRUARY 2022



## អ្នកនិពន្ធ

ជា លាងស្រ៊ុន[1], ហុក លីដា[1], ជា គឹមអ៊ិន[2]

[1] មជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ
[2] មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ កម្ពុជា

## សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

បណ្ឌិត ជា លាងស្រ៊ុន
លេខទូរស័ព្ទ៖ (៨៥៥)១២ ២៨០ ២៤៩
cleangsrun@rua.edu.kh

## កម្មវិធីផ្សព្វផ្សាយកសិកម្មស៊ីសែន

**CE SAIN Agricultural Extension Program**

កម្មវិធីនេះបំពេញមុខងារជាវេទិកាមួយដែលជួយសម្របសម្រួលដល់កសិករ ស្ថាប័នអប់រំ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការទទួលព័ត៌មានពីចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ទាក់ទងនឹងបច្ចេកទេសកសិកម្មដើម្បីធានាដល់ការផ្សព្វផ្សាយការអនុវត្តការគ្រប់គ្រង់កសិកម្មល្អៗ។ កម្មវិធីនេះជួយធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និងការអនុវត្តបច្ចេកទេសកសិកម្មដោយផ្អែកលើនវានុវត្តន៍ និងការស្រាវជ្រាវវិទ្យាសាស្ត្រជាមូលដ្ឋាន។

## ១. តើគម្របរស់ជាអ្វី?



គម្របរស់ ជាប្រភេទដំណាំដែលមានអាយុកាលមួយឆ្នាំ ឬច្រើនឆ្នាំ ហើយត្រូវបានគេដាំដុះជាមួយដំណាំចំបង ឬ ដំណាំសេដ្ឋកិច្ចក្នុងគោលបំណងធ្វើជាគម្របដី។ គម្របរស់ដែលត្រូវបានគេដាំដុះញឹកញាប់មានដូចជា៖ សណ្តែកព្រៃ សណ្តែកអង្រែ ស្នោគោក...។

## ២. អត្ថប្រយោជន៍នៃគម្របរស់

- ផ្តល់ជាគម្របដី ដែលអាចកាត់បន្ថយស្មៅចង្រៃ និងរក្សាសំណើមដី
- គម្របរស់ចាក់ឫសបានជ្រៅ ដែលធ្វើឲ្យដីធូរ និងកាត់បន្ថយការហូរច្រោះ
- បង្កើនគុណភាពដី និងសារធាតុចិញ្ចឹម នៅក្នុងដីដូចជា អាសូត និងផូស្វ័រ
- កាត់បន្ថយការបំផ្លាញពីសត្វល្អិត និងជម្ងឺ
- បង្កើនទិន្នផលដំណាំ
- អាចប្រើប្រាស់ធ្វើជាចំណីសត្វ




## ៣. ការជ្រើសរើសប្រភេទគម្របរស់សម្រាប់ដាំដុះជាមួយដំណាំបន្លែ

ដំណាំគម្របរស់ដែលអាចដាំដុះជាមួយដំណាំបន្លែបានគួរមានលក្ខណៈដូចខាងក្រោម៖

- មានកំពស់ទាបដែលមិនរារាំងដល់ការលូតលាស់របស់ដំណាំបន្លែ
- លូតលាស់លឿន ដើម្បីគ្របដីបានឆាប់រហ័ស
- មានប្រព័ន្ធឫសជ្រៅ
- មានភាពទន់ទ្រាំនឹងកង្វះទឹក និងសារធាតុចិញ្ចឹម
- មានសមត្ថភាពក្នុងការបង្កើនជីជាតិដី (ឧ. គម្របរស់អំបូរសណ្តែក។ ល ។)

## ៤. ការជ្រើសរើសប្រភេទដំណាំបន្លែដែលសមស្រប

- មានអាយុកាលលូតលាស់យូរ (ច្រើនជាង២ខែ)
- មានកម្ពស់ខ្ពស់ (ខ្ពស់ជាង០,៥ម)
- ដំណាំដែលមានការដាំដុះដោយការស្ទូងកូន ឬដំណាំដែលដាំដុះដោយគ្រាប់ជាជួរ ដំណាំដែលសមស្របមានដូចជា៖ ប៉េងប៉ោះ ម្ទេស ត្រប់ ស្ពៃក្តោប ពោតដំណើប សណ្តែកគួរ ។ ល ។



## ៥. ការដាំដុះ និងគ្រប់គ្រង

- ត្រូវដាំដំណាំគម្របរស់យ៉ាងហោច២-៤សប្តាហ៍មុនពេលដាំដុះដំណាំបន្លែ
- ជម្រះ ឬកាត់តម្រឹមដំណាំគម្របរស់នៅជុំវិញគល់ដំណាំបន្លែ ដើម្បីកាត់បន្ថយការប្រកួតប្រជែង (ប្រហែល៥-១០ស.ម ជុំវិញគល់ដំណាំ)
- ស្រោចស្រពដល់ដំណាំបន្លែអោយមានគ្រប់គ្រាន់ (ប្រព័ន្ធដំណក់ទឹកជាជម្រើសល្អប្រសើរ)
- ស្រោចស្រពដល់ដំណាំគម្របរស់នៅពេលដែលចាំបាច់ ក្នុងបរិមាណទឹកតិចតួច
- នៅក្នុងលក្ខខណ្ឌមានសំណើមខ្ពស់ គេគួរតែកាត់គម្របរស់អោយនៅកម្ពស់ទាប ដើម្បីជៀសវាងបង្ករជាជម្រកដល់ភ្នាក់ងារបង្ករជម្ងឺ
- បន្ទាប់ពីប្រមូលផលដំណាំ គេក៏អាចភ្ជួរលុបគម្របរស់ដើម្បីធ្វើជាជីស្រស់ ឬកាត់គម្របរស់ដើម្បីធ្វើជាំដំណីសត្វ ។